# សំណួរសួរញឹកញាប់
# ពីអ្នកស្រឡាញ់ភេទដូចគ្នា



# FAQs

អង្គការសហគមន៍ឥន្ទធនូកម្ពុជា

ROCK

RAINBOW COMMUNITY KAMPUCHEA ORGANISATION

ជារឿយៗ សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាតែងត្រូវបានសួរសំណួរស្រដៀងៗគ្នា ដែលអាចធ្វើឲ្យយើងមានអារម្មណ៍មិនស្រណុក។ ពួកយើងជឿថា ការជជែកពិភាក្សាក្នុងន័យគោរពគ្នា អាចជួយឲ្យមនុស្សក្នុងសង្គមយល់ពីគ្នា ទទួលយកការពិត និងគាំទ្រគ្នាបានកាន់តែប្រសើរ។ បើអ្នកងឿងឆ្ងល់ ឬកំពុងស្វែងរកការបកស្រាយពាក់ព័ន្ធនឹងអ្នកស្រឡាញ់ភេទដូចគ្នា ពួកយើងរៀបរៀងខិត្តប័ណ្ណព័ត៌មាននេះដែលអាចជួយអ្នកបាន។

## ១. តើអ្នកស្រឡាញ់ភេទដូចគ្នាជានរណា?

ពាក្យនេះប្រើក្រោមន័យរួមនៃបុគ្គលជា៖ បុរសស្រឡាញ់បុរស ស្ត្រីស្រឡាញ់ស្ត្រី អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ និងអន្តរភេទ ដែលភាសាអង់គ្លេសហៅថា LGBTIQ។

## ២. តើអ្វីជាពាក្យពេញនៃ LGBTIQ?

L = Lesbian : ស្ត្រីស្រឡាញ់ស្ត្រី
G= Gay : បុរសស្រឡាញ់បុរស
B= Bisexual : អ្នកស្រឡាញ់ពីរភេទ (ទាំងបុរសនិងស្ត្រី)
T= Transgender: អ្នកផ្លាស់ប្តូរយេនឌ័រ
I = Intersex : អន្តរភេទ (បុគ្គលដែលកើតមកមានអវៈយវៈភេទស្រីផងប្រុសផង)
Q = Questioning :អ្នកកំពុងស្វែងយល់ពីអត្ត-សញ្ញាណយេនឌ័រនិងអារម្មណ៍ស្នេហាខ្លួនឯង ឬ
= Queer : អ្នកមិនកំណត់អត្តសញ្ញាណយេនឌ័រខ្លួនឯង

LGBTIQ

## ៣. តើអ្នកស្រឡាញ់ភេទដូចគ្នាមានន័យដូចម្តេច?

- បុគ្គលដែលមានរូបរាងកាយ និងភេទពីកំណើត មិនត្រូវគ្នាជាមួយអារម្មណ៍នៃអត្តសញ្ញាណខ្លួន។ បុគ្គលខ្លះស្លៀកពាក់ និងបង្ហាញអាកប្បកិរិយាឲ្យត្រូវទៅតាមអត្តសញ្ញាណដែលគេស្រឡាញ់ ឬភាពជា ខ្លួនឯង
- បុគ្គលដែលមានអារម្មណ៍មនោសញ្ចេតនាស្នេហាជាមួយបុគ្គលម្នាក់ទៀតដែលមានភេទដូចគ្នា ឬទាំងពីរភេទ។



## ៤. ហេតុអ្វីបានស្រឡាញ់ភេទដូចគ្នា?

- វាជាធម្មជាតិរបស់មនុស្សម្នាក់ៗ ដែលមានអារម្មណ៍ស្នេហាកប់យ៉ាងជ្រាលជ្រៅនៅក្នុងបេះដូង
- ក្ដីស្រឡាញ់មិនសំដៅត្រឹមតែភេទរបស់បុគ្គលទេ
- ដោយសារមនុស្សភាគច្រើនបានកំណត់លក្ខខណ្ឌស្នេហាត្រឹមតែរវាង ភេទប្រុសនិងស្រី ទើបបានជាពិបាកទទួលយកក្ដីស្រឡាញ់របស់បុគ្គលមានភេទដូចគ្នា
- សេចក្ដីស្នេហាផុសចេញពីមនោសញ្ចេតនា ការយល់ចិត្ត ការគោរព ភាពចុះសម្រុង និងសុភមង្គលដែលបុគ្គលមានចំពោះគ្នាហើយផ្ដល់ឲ្យគ្នា។

## ៥. តើស្រឡាញ់ភេទដូចគ្នាដោយសារខូចចិត្តជាមួយស្នេហាភេទផ្ទុយគ្នា មែនឬទេ?

- មិនពិតទេ ព្រោះអារម្មណ៍នៃសេចក្តីស្រឡាញ់មិនអាចបង្ខំបានឡើយ
- អ្នកស្រឡាញ់ភេទដូចគ្នាមួយចំនួនធ្លាប់រៀបការជាមួយបុគ្គលមានភេទផ្ទុយពីខ្លួន ហើយបែកបាក់គ្នាដោយប្រការផ្សេងៗ ហើយមានស្នេហាថ្មីជាមួយបុគ្គលមានភេទដូចគ្នា ក៏មិនអាចបញ្ជាក់ថាដោយសារការខូចចិត្តពីអតីតកាលដែរ
- បុគ្គលម្នាក់ៗត្រូវការពេលវេលា ដើម្បីស្វែងយល់ពីខ្លួនឯង ទាំងអារម្មណ៍ស្នេហា មនុស្សដែលយើងស្រឡាញ់ និងការប្តេជ្ញាចិត្តរួមរស់ជាមួយ។

## ៦. តើការស្រឡាញ់ភេទដូចគ្នាមានអនាគតដែរឬទេ?

• អនាគតមានន័យទូលំទូលាយណាស់
• ប្រសិនបើសំដៅត្រឹមការរៀបការ មានប្ដីប្រពន្ធ បង្កើតកូនបន្តពូជពង្សវង្សត្រកូល ថែរក្សាគ្នា និង កសាងជីវភាពគ្រួសារឲ្យរុងរឿង នោះវាជាជម្រើស និងសិទ្ធិសម្រេចចិត្តរបស់បុគ្គល។

## ៧. តើអ្នកស្រឡាញ់ភេទដូចគ្នា កសាងគ្រួសារដោយរបៀបណា?

• ការបង្កើតគ្រួសារមានទម្រង់ និង មធ្យោបាយជាច្រើន៖ រស់នៅជាមួយមនុស្សដែលខ្លួនស្រឡាញ់ ដោយមិនចាំបាច់មានកូនចៅ ធ្វើជាអាណាព្យាបាលសាច់ញាតិ សុំកូន ធម្មតា ឬសុំកូនពេញលេញទៅតាមច្បាប់កំណត់។

## ៨. តើអ្នកស្រឡាញ់ភេទដូចគ្នារស់នៅយ៉ាងដូចម្តេច?

- រស់នៅដូចមនុស្សដទៃក្នុងសង្គម ដូចជាខិតខំរៀនសូត្រ ធ្វើការ ប្រកបរបរចិញ្ចឹមជីវិត ជួយផ្គត់ផ្គង់ និងថែរក្សាគ្រួសារ
- មានក្តីសុបិន បំណងប្រាថ្នា និងគោលដៅជីវិតដែលជោគជ័យ រីករាយ និងសុភមង្គល
- មានមិត្តភក្តិ ការគោរពរាប់អាន និង ជួយយកអាសារអ្នកជិតខាង ចូលរួមសកម្មភាពសង្គម វប្បធម៌ ប្រពៃណី និង សាសនា
- ជីវិតគូស្រករគឺរួមទាំងសុខ និងទុក្ខជាមួយគ្នា។

## ៩. តើស្រឡាញ់ភេទដូចគ្នាមានប្រយោជន៍អ្វីខ្លះ?

- អាចរស់នៅជាមួយការពិតនៃភាពជាខ្លួនឯងយ៉ាងស្ងប់សុខ
- អាចរស់នៅជាមួយអ្នកដែលយើងស្រឡាញ់ដោយសុភមង្គល។

## ១០. តើការស្រឡាញ់ភេទដូចគ្នាជាស្នេហាអមតៈដែរឬទេ?

• សេចក្ដីស្នេហាដែលគង់វង្សគឺអាស្រ័យលើបុគ្គលពីរនាក់ ដែលមានក្ដីស្រឡាញ់ ការយល់ចិត្តគ្នា ឆន្ទៈ ការប្ដេជ្ញាចិត្ត ការគោរព ការទទួលខុសត្រូវ ថេះថៃរក្សាគ្នា ហើយគ្រួសារគាំទ្រ

• ការបែកបាក់ស្នេហាអាចបណ្ដាលមកពីគ្រួសារ និងសហគមន៍មិនទទួលស្គាល់ ការរើសអើង អំពើហិង្សាភាព មិនចុះសម្រុងគ្នា និងអស់ក្ដីស្រឡាញ់។

## ១១. តើអ្នកស្រឡាញ់ភេទដូចគ្នា រួមភេទដោយរបៀបណា?

• ការរួមភេទមានលក្ខណៈខុសៗគ្នា សម្រាប់បុគ្គលម្នាក់ៗ

• ការរួមភេទជារឿងឯកជនរបស់បុគ្គល ដែលយើងម្នាក់ៗគួរគោរព។

## ១២. តើអ្នកស្រឡាញ់ភេទដូចគ្នា ប្រចណ្ឌច្រើន និងគិតតែពីរឿងរួមភេទមែនទេ?

- ការប្រចណ្ឌគឺជាអារម្មណ៍ធម្មជាតិដែលមាននៅក្នុងខ្លួនមនុស្សគ្រប់រូប ដែលមានស្នេហាទាំងអ្នកដែលស្រឡាញ់ភេទដូចគ្នា និងស្រឡាញ់ភេទផ្ទុយគ្នា
- មិនប្រាកដថាបុគ្គលម្នាក់ ដែលមានអារម្មណ៍ស្រឡាញ់ ឬស្នេហាសុទ្ធតែ មានអារម្មណ៍ ឬចំណង់ផ្លូវភេទទេ
- អារម្មណ៍ផ្លូវភេទ ឬការរួមភេទគឺជាអារម្មណ៍ធម្មជាតិ និងជាសិទ្ធិរបស់បុគ្គលដែលពេញវ័យ ហើយមានការព្រមព្រៀងរវាងដៃគូ (តាមច្បាប់នៃប្រទេសកម្ពុជាគឺចាប់ពីអាយុ១៥ឆ្នាំឡើងទៅ)។

## ១៣. តើអ្នកស្រឡាញ់ភេទដូចគ្នាមាន ភាពអាម៉ាស់ចំពោះខ្លួនឯងដែរឬទេ?

- ដំបូងបុគ្គលមួយចំនួនអាចមានអារម្មណ៍ខ្មាសអៀន ឆ្ងល់ ខឹងដោយសារមិនទាន់យល់ពីខ្លួនឯង

ច្បាស់ ហើយវប្បធម៌ប្រពៃណីក៏បង្រៀនថា ការស្រ-
ឡាញ់ភេទដូចគ្នាគឺខុសធម្មជាតិ ខុសគេ មិនប្រក្រ-
តី និងមិនធម្មតា

- អ្វីដែលសំខាន់គឺបុគ្គលម្នាក់ៗជឿជាក់លើខ្លួនឯង ហើយរស់នៅជាមួយ នឹងភាពពិតរបស់ខ្លួន
- យើងមានក្តីសង្ឃឹមថា ថ្ងៃណាមួយ គ្រួសារ មិត្តភក្តិ និងសហគមន៍យល់ និងគោរពយើង។

## ១៤. ហេតុអ្វីអ្នកស្រឡាញ់ភេទដូចគ្នា មិនគិត និងធ្វើតាមបំណងគ្រួសារ?

- គ្រប់គ្នាសុទ្ធតែគិតគូរ និងស្រឡាញ់ គ្រួសារ ព្រោះគ្រួសារមានន័យធំធេង ហើយជាទីកក់ក្តៅ
- ដោយសារស្រឡាញ់ ឲ្យតម្លៃ និងគោរពគ្រួសារ ទើបយើងស្មោះត្រង់ និងប្រាប់ការពិត
- ភាពអត់ធ្មត់ ការខិតខំប្រឹងប្រែងរស់នៅជាមនុស្សល្អក្នុងសង្គមគឺដើម្បីបញ្ជាក់ពីភាពស្អាតស្អំ និងបំ-ណងការពារគ្រួសារ។

## ១៥. តើគ្រួសារមានប្រតិកម្មយ៉ាងម៉េចនៅពេលដឹងការពិតថា អ្នកស្រឡាញ់ភេទដូចគ្នា?

- ដំបូងគឺតក់ស្លុត ខឹងសម្បា តូចចិត្ត កើតទុក្ខ និងអាម៉ាស់
- គ្រួសារនឹងយល់ តាមរយៈពេលវេលា ការព្យាយាមភាពអំណត់ និងការជជែកពិភាក្សាមានហេតុផល
- យើងជឿថាឪពុកម្តាយដឹងពីអត្តចរិតពិតរបស់កូន ព្រោះគាត់ជាអ្នកចិញ្ចឹមបីបាច់យើង។

## ១៦. តើការបង្ខំរៀបការជាមួយភេទផ្ទុយគ្នាអាចព្យាបាល ឬផ្លាស់ប្តូរអ្នកបានទេ?

- ការស្រឡាញ់ភេទដូចគ្នាមិនមែនជាជំងឺទេ ហើយអ្នកស្រឡាញ់ភេទដូចគ្នាក៏មិនមែនជាអ្នកជំងឺដែរ
- ការស្រឡាញ់ភេទដូចគ្នាត្រូវបានដកចេញពីបញ្ជីជំងឺផ្លូវចិត្ត (អង្គការសុខភាពពិភពលោកឆ្នាំ១៩៩០ និងវិទ្យាស្ថានចិត្តវិទ្យាចិន ឆ្នាំ២០១១)

• ការបង្ខំកូនចៅឲ្យរៀបការជាមួយភេទផ្ទុយគ្នា គឺអាចជួយលាក់បាំង លើកមុខមាត់គ្រួសារ ប៉ុន្តែ មិនមែនជាក្ដីសុខពិតប្រាកដរបស់កូនឡើយ។

## ១៧. តើអ្នកស្រឡាញ់ភេទដូចគ្នាធ្វើឲ្យដាច់ពូជ ប៉ះពាល់ដល់កំណើនប្រជាជន ដែលជាធនធានមនុស្សឬទេ?

• អ្នកស្រឡាញ់ភេទដូចគ្នាជាផ្នែកមួយនៃមនុស្សជាតិតាំងពីមនុស្សបានចាប់កំណើតមកម្ល៉េះ

• អ្នកស្រឡាញ់ភេទដូចគ្នាជាមនុស្សភាគតិចប្រមាណ១០ភាគរយនៃចំនួនប្រជាជនសកលលោកសរុប៧,៨ពាន់លាននាក់ (២០២០)។ ដូច្នេះ ៩០ភាគរយ គឺជាប្រជាជនស្រឡាញ់ភេទផ្ទុយគ្នា ដែលអាចបង្កកំណើត ឬបន្តពូជបានជាបន្តបន្ទាប់។

## ១៨. តើអ្នកស្រឡាញ់ភេទដូចគ្នាធ្វើឲ្យប៉ះពាល់ដល់វប្បធម៌ប្រពៃណីដែរឬទេ?

• អ្នកស្រឡាញ់ភេទដូចគ្នាមិនបានបន្ថោកតម្លៃបំផ្លិចបំផ្លាញ និងផ្លាស់ប្តូរវប្បធម៌ខ្មែរទេ។ មានរូបភាពអ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងទម្រង់សិល្បៈ និងស្ថាបត្យកម្មបុរាណ ដែលជាប្រពៃណីវប្បធម៌ដ៏យូរលង់

• ចាប់ពីឆ្នាំ២០០៩ មានកំណើនអ្នកស្រឡាញ់ភេទដូចគ្នាបង្ហាញភាពពិតខ្លួនឯង និងមនោសញ្ចេតនារបស់ខ្លួន ដែលអាចធ្វើឲ្យសាធារណជនភ្ញាក់ផ្អើល និងព្រួយបារម្ភ។ នេះក៏ព្រោះតែប្រជាជនខ្មែរបើកចិត្តទូលាយជាងមុន រាជរដ្ឋាភិបាលកម្ពុជាគាំទ្រ ការពារ និងអំពាវនាវឲ្យប្រជាជនរស់នៅដោយភាពសុខដុមទើបធ្វើឲ្យអ្នកស្រឡាញ់ភេទដូចគ្នាមានភាពកក់ក្តៅ សុវត្ថិភាព និងក្លាហានរស់នៅដោយបើកចំហរ។

## ១៩. តើកម្ពុជាមានច្បាប់អាពាហ៍ពិពាហ៍អ្នកស្រឡាញ់ភេទដូចគ្នាឬទេ?

- ប្រទេសកម្ពុជាមិនទាន់មានច្បាប់អនុញ្ញាតិ និងទទួលស្គាល់អាពាហ៍ពិពាហ៍ ក៏ដូចជាសហព័ទ្ធភេទដូចគ្នានៅឡើយទេ
- ច្បាប់នៃប្រទេសកម្ពុជាក៏មិនបានហាមប្រាម ឬដាក់ទោសទណ្ឌអ្នកស្រឡាញ់ភេទដូចគ្នាក្នុងការរួមរស់ជាគូរស្រករដែរ។

## ២០. តើអ្នកស្រឡាញ់ភេទដូចគ្នារៀបការតាមប្រពៃណីខុសច្បាប់ដែរឬទេ?

- ប្រទេសកម្ពុជាគ្មានច្បាប់ហាមប្រាម ឬដាក់ទោសទណ្ឌចំពោះពិធីរៀបការ និងជប់លៀងតាមទំនៀមទំលាប់ប្រពៃណីរបស់គូស្រករអ្នកស្រឡាញ់ភេទដូចគ្នាទេ។

## ២១. តើអ្នកស្រឡាញ់ភេទដូចគ្នាមានសិទ្ធិអ្វីខ្លះ?

• មានសិទ្ធិ និងករណីកិច្ច ដូចប្រជាពលរដ្ឋដទៃទៀត ដែលធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ

• ដោយសារកង្វះការទទួលស្គាល់ និងការការពារផ្នែកច្បាប់នៃអាពាហ៍ពិពាហ៍ និងគ្រួសារក្នុងន័យសហព័ទ្ធ អ្នកស្រឡាញ់ភេទដូចគ្នាពុំមានសិទ្ធិ និងលទ្ធភាពពេញលេញ ដើម្បីទទួលបាន និងការពារផលប្រយោជន៍ ឬអនុភាពសំខាន់ៗដូចជា កម្មសិទ្ធិលើទ្រព្យសម្បត្តិរួម គ្រប់គ្រង ចិញ្ចឹម បីបាច់ថែរក្សាកូន ការទទួលមរតក ការបង់ពន្ធ និងគោលនយោបាយកិច្ចគាំពារសង្គមផ្សេងៗ។

អង្គការសហគមន៍ឥន្ទធនូកម្ពុជា គឺជាអង្គការរបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា មានចក្ខុវិស័យសម្រាប់ប្រទេសកម្ពុជា ជាទីកន្លែងដែលប្រជាពលរដ្ឋស្រឡាញ់ភេទដូចគ្នា មានអារម្មណ៍រីករាយចំពោះខ្លួនឯង និងរស់នៅយ៉ាងសប្បាយ ដោយមានការការពារសិទ្ធិ ទទួលបានការគោរព ការទទួលស្គាល់ពេញលេញ និងស្មើភាពគ្នាពីគ្រប់ផ្នែកនៃសង្គម ជាពិសេសពីគ្រួសារ សហគមន៍ និងអាជ្ញាធរ។



សម្រាប់ព័ត៌មានលម្អិតសូមទាក់ទង
**អង្គការសហគមន៍ឥន្ទធនូ(រ៉ក់)**

លេខទូរស័ព្ទ: (+៨៥៥)១២ ៤៨ ១៥ ៦១
(+៨៥៥) ៩០ ៨៧ ៥៩២៩

អ៊ីម៉ែល: contact@rockcambodia.org

គេហទំព័រ: www.rockcambodia.org

ហ្វេសប៊ុក: RoCKHMERLGBT2009

អាសយដ្ឋាន: ផ្ទះលេខ#៤៧E1 ផ្លូវ៣៥០
សង្កាត់បឹងកេងកង៣
ខណ្ឌបឹងកេងកង រាជធានី
ភ្នំពេញ